ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសាធារណការ និងដឹកជញ្ជូន

លេខ:...៣៤៤...ប្រ.ក.សក

រាជធានីភ្នំពេញ, ថ្ងៃទី..០៦...ខែ..១១.....ឆ្នាំ២០១៧

# ប្រកាស
# ស្តីពី
# លក្ខខណ្ឌ និងនីតិវិធីនៃការចេញលិខិតអនុញ្ញាតឲ្យ
# នីតិបុគ្គលធ្វើអាជីវកម្មដឹកជញ្ជូនផ្លូវគោកក្នុងប្រទេស

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៤១៦/៣៦៨ចុះថ្ងៃទី០៤ខែមេសាឆ្នាំ២០១៦ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសាធារណការនិងដឹកជញ្ជូន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១១៥/០០១ ចុះថ្ងៃទី០៩ ខែមករា ឆ្នាំ២០១៥ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក
- បានឃើញអនុក្រឹត្យលេខ២១៦ អនក្រ.បក ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងសាធារណការនិងដឹកជញ្ជូន
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសាធារណការនិងដឹកជញ្ជូន



មហាវិថីព្រះនរោត្តម, ភ្នំពេញ ទូរស័ព្ទ-ទូរសារៈ (៨៥៥) ២៣ ៤២៧ ៨៦២

## សម្រេច

**ប្រការ១.-**

ប្រកាសនេះ មានគោលបំណងគ្រប់គ្រងក្រុមហ៊ុនដែលធ្វើអាជីវកម្មដឹកជញ្ជូនផ្លូវគោកនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ២.-**

ប្រកាសនេះ មានគោលដៅកំណត់អំពីលក្ខខណ្ឌនិងនីតិវិធីនៃការចុះបញ្ជីធ្វើអាជីវកម្មដឹកជញ្ជូន និងការផ្តល់លិខិតអនុញ្ញាតឲ្យនីតិបុគ្គលធ្វើអាជីវកម្មដឹកជញ្ជូនផ្លូវគោកនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ៣.-**

ប្រកាសនេះ មានវិសាលភាពអនុវត្តចំពោះក្រុមហ៊ុនធ្វើអាជីវកម្មដឹកជញ្ជូនផ្លូវគោកជាអាទិ៍ ក្រុមហ៊ុនធ្វើអាជីវកម្មដឹកជញ្ជូនទំនិញ អ្នកដំណើរ ភ្នាក់ងារផ្តល់សេវាដឹកជញ្ជូន និងសេវាកម្មជួលរថយន្តនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ៤.-**

វាក្យសព្ទដែលប្រើប្រាស់ក្នុងប្រកាសនេះ៖

- ក្រុមហ៊ុនធ្វើអាជីវកម្មដឹកជញ្ជូនទំនិញ អ្នកដំណើរ សំដៅលើនីតិបុគ្គលដែលធ្វើអាជីវកម្មដឹកជញ្ជូនទំនិញ ដឹកជញ្ជូនអ្នកដំណើរ ដោយប្រើប្រាស់រថយន្ត។
- ភ្នាក់ងារផ្តល់សេវាដឹកជញ្ជូន សំដៅលើនីតិបុគ្គលដែលផ្តល់សេវាកម្មដឹកជញ្ជូនទំនិញ ឬដឹកជញ្ជូនអ្នកដំណើរ ដោយមាន ឬគ្មានរថយន្ត ដើម្បីយកកម្រៃ ក្នុងនោះរាប់បញ្ចូលទាំងភ្នាក់ងារផ្តល់សេវាដឹកជញ្ជូន ដែលធ្វើប្រតិបត្តិការ ឬគាំទ្រសកម្មភាពដឹកជញ្ជូនដោយប្រព័ន្ធចែករំលែកយានជំនិះ តាមមធ្យោបាយអេឡិចត្រូនិក។
- សេវាកម្មជួលរថយន្ត សំដៅលើនីតិបុគ្គលដែលផ្តល់សេវាជួលរថយន្តសម្រាប់ជាមធ្យោបាយដឹកជញ្ជូនទំនិញ ឬអ្នកដំណើរ។

**ប្រការ៥.-**

ក្រុមហ៊ុនដែលធ្វើអាជីវកម្មដឹកជញ្ជូនទំនិញ អ្នកដំណើរ ភ្នាក់ងារផ្តល់សេវាដឹកជញ្ជូន និងសេវាកម្មជួលរថយន្តត្រូវមានវិញ្ញាបនបត្រចុះបញ្ជីធ្វើអាជីវកម្មដឹកជញ្ជូន និងលិខិតអនុញ្ញាតឲ្យនីតិបុគ្គលធ្វើអាជីវកម្មដឹកជញ្ជូនផ្លូវគោកក្នុងប្រទេស។

នីតិបុគ្គល ឬតំណាងស្របច្បាប់ ត្រូវដាក់ពាក្យសុំវិញ្ញាបនបត្រចុះបញ្ជីធ្វើអាជីវកម្មដឹកជញ្ជូន និងលិខិតអនុញ្ញាតឲ្យនីតិបុគ្គលធ្វើអាជីវកម្មដឹកជញ្ជូនផ្លូវគោកក្នុងប្រទេស ដែលមានអាសយដ្ឋាន transportlicense.mpwt.gov.kh ទៅទីតាំងផ្តល់សេវាសាធារណៈរបស់ក្រសួងសាធារណការនិងដឹកជញ្ជូនតាមគំនូសបំព្រួញដូចមានចែងក្នុង**ឧបសម្ព័ន្ធទី១** និងត្រូវភ្ជាប់សំណុំឯកសារដូចខាងក្រោម៖

ក- ការផ្តល់វិញ្ញាបនបត្រចុះបញ្ជីធ្វើអាជីវកម្មដឹកជញ្ជូន និងលិខិតអនុញ្ញាតឲ្យនីតិបុគ្គលធ្វើអាជីវកម្មដឹកជញ្ជូនទំនិញ អ្នកដំណើរ ភ្នាក់ងារផ្តល់សេវាដឹកជញ្ជូន និងសេវាកម្មជួលរថយន្ត លើកដំបូង ត្រូវភ្ជាប់សំណុំឯកសារ៖

- អត្តសញ្ញាណរបស់ប្រធានក្រុមហ៊ុន៖

- ○ អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ សៀវភៅគ្រួសារ ឬសៀវភៅស្នាក់នៅ(ករណីក្រុមហ៊ុនសញ្ជាតិខ្មែរ)
- ○ លិខិតឆ្លងដែន(ករណីក្រុមហ៊ុនសញ្ជាតិបរទេស)
- វិញ្ញាបនបត្របញ្ជាក់ការចុះបញ្ជីពាណិជ្ជកម្ម
- លក្ខន្តិកៈក្រុមហ៊ុន
- ស្ថិតិរថយន្ត(មិនតម្រូវសម្រាប់ភ្នាក់ងារផ្តល់សេវាដឹកជញ្ជូន)
- លិខិតបញ្ជាក់ទីតាំងចំណតរថយន្ត(មិនតម្រូវសម្រាប់ភ្នាក់ងារផ្តល់សេវាដឹកជញ្ជូន)
- បណ្ណប៉ាតង់។

ខ-ការបន្តលិខិតអនុញ្ញាតឲ្យនីតិបុគ្គលធ្វើអាជីវកម្មដឹកជញ្ជូនទំនិញ អ្នកដំណើរ ភ្នាក់ងារផ្តល់សេវាដឹកជញ្ជូន និងសេវាកម្មជួលរថយន្ត ត្រូវភ្ជាប់សំណុំឯកសារៈ

- អត្តសញ្ញាណរបស់ប្រធានក្រុមហ៊ុនៈ
  - ○ អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ សៀវភៅគ្រួសារ ឬសៀវភៅស្នាក់នៅ(ករណីក្រុមហ៊ុនសញ្ជាតិខ្មែរ)
  - ○ លិខិតឆ្លងដែន(ករណីក្រុមហ៊ុនសញ្ជាតិបរទេស)
- វិញ្ញាបនបត្រចុះបញ្ជីធ្វើអាជីវកម្មដឹកជញ្ជូនផ្លូវគោកក្នុងប្រទេស
- វិញ្ញាបនបត្របញ្ជាក់ការចុះបញ្ជីពាណិជ្ជកម្ម
- បណ្ណប៉ាតង់
- ស្ថិតិរថយន្ត(មិនតម្រូវសម្រាប់ភ្នាក់ងារផ្តល់សេវាដឹកជញ្ជូន)

គ-ការផ្តល់ និងបន្តលិខិតអនុញ្ញាតឲ្យនីតិបុគ្គលបើកសាខាធ្វើអាជីវកម្មដឹកជញ្ជូនទំនិញ អ្នកដំណើរ ភ្នាក់ងារផ្តល់សេវាដឹកជញ្ជូន និងសេវាកម្មជួលរថយន្ត ត្រូវភ្ជាប់សំណុំឯកសារៈ

- វិញ្ញាបនបត្រចុះបញ្ជីធ្វើអាជីវកម្មដឹកជញ្ជូនផ្លូវគោកក្នុងប្រទេស
- លិខិតអនុញ្ញាតឲ្យនីតិបុគ្គលធ្វើអាជីវកម្មដឹកជញ្ជូនផ្លូវគោកក្នុងប្រទេស
- លិខិតបញ្ជាក់អំពីទីស្នាក់ការសាខាក្រុមហ៊ុន
- បណ្ណប៉ាតង់។

ទម្រង់ពាក្យសុំនៃការចុះបញ្ជីធ្វើអាជីវកម្មដឹកជញ្ជូនផ្លូវគោកក្នុងប្រទេស លិខិតអនុញ្ញាតឲ្យនីតិបុគ្គលធ្វើអាជីវកម្មដឹកជញ្ជូនផ្លូវគោកក្នុងប្រទេស លិខិតអនុញ្ញាតឲ្យនីតិបុគ្គលបើកសាខាធ្វើអាជីវកម្មដឹកជញ្ជូនផ្លូវគោកក្នុងប្រទេស និងទម្រង់វិញ្ញាបនបត្រចុះបញ្ជីធ្វើអាជីវកម្មដឹកជញ្ជូនផ្លូវគោកក្នុងប្រទេស លិខិតអនុញ្ញាតឲ្យនីតិបុគ្គលធ្វើអាជីវកម្មដឹកជញ្ជូនផ្លូវគោកក្នុងប្រទេស លិខិតអនុញ្ញាតឲ្យនីតិបុគ្គលបើកសាខាធ្វើអាជីវកម្មដឹកជញ្ជូនផ្លូវគោកក្នុងប្រទេស មានចែងនៅក្នុង**ឧបសម្ព័ន្ធទី២** នៃប្រកាសនេះ។

**ប្រការ៦.-**

- វិញ្ញាបនបត្រចុះបញ្ជីធ្វើអាជីវកម្មដឹកជញ្ជូនផ្លូវគោកក្នុងប្រទេស មានសុពលភាពអចិន្ត្រៃយ៍

- លិខិតអនុញ្ញាតឲ្យនីតិបុគ្គលធ្វើអាជីវកម្មដឹកជញ្ជូនផ្លូវគោកក្នុងប្រទេស ឬលិខិតអនុញ្ញាតឲ្យនីតិបុគ្គលបើកសាខាធ្វើអាជីវកម្មដឹកជញ្ជូនផ្លូវគោកក្នុងប្រទេស មានសុពលភាព២(ពីរ)ឆ្នាំ។

**ប្រការ៧.-**

វិញ្ញាបនបត្រចុះបញ្ជីធ្វើអាជីវកម្មដឹកជញ្ជូនផ្លូវគោកក្នុងប្រទេស និងលិខិតអនុញ្ញាតឲ្យនីតិបុគ្គលធ្វើអាជីវកម្មដឹកជញ្ជូនផ្លូវគោកក្នុងប្រទេស ត្រូវអស់សុពលភាពដោយស្វ័យប្រវត្តិ ក្នុងករណីដូចខាងក្រោម៖

- សាលក្រមតុលាការបានសម្រេចហាមឃាត់ការធ្វើអាជីវកម្មដឹកជញ្ជូនផ្លូវគោករបស់ក្រុមហ៊ុន
- ក្រុមហ៊ុនត្រូវបានលុបឈ្មោះចេញពីបញ្ជីពាណិជ្ជកម្ម។

លិខិតអនុញ្ញាតឲ្យនីតិបុគ្គលបើកសាខាធ្វើអាជីវកម្មដឹកជញ្ជូនផ្លូវគោកក្នុងប្រទេស ត្រូវអស់សុពលភាពដោយស្វ័យប្រវត្តិ ក្នុងករណីដូចខាងក្រោម៖

- លិខិតអនុញ្ញាតឲ្យនីតិបុគ្គលធ្វើអាជីវកម្មដឹកជញ្ជូនផ្លូវគោកក្នុងប្រទេសអស់សុពលភាព
- សាលក្រមតុលាការបានសម្រេចហាមឃាត់ការធ្វើអាជីវកម្មដឹកជញ្ជូនផ្លូវគោករបស់ក្រុមហ៊ុន ឬសាខាក្រុមហ៊ុន
- ក្រុមហ៊ុនបានបិទសាខារបស់ខ្លួន។

**ប្រការ៨.-**

ក្រុមហ៊ុនដែលមិនមានលិខិតអនុញ្ញាតឲ្យនីតិបុគ្គលធ្វើអាជីវកម្មដឹកជញ្ជូនផ្លូវគោកក្នុងប្រទេស ឬមានលិខិតអនុញ្ញាតឲ្យនីតិបុគ្គលធ្វើអាជីវកម្មដឹកជញ្ជូនផ្លូវគោកក្នុងប្រទេសដែលអស់សុពលភាព មិនមានសិទ្ធិស្នើសុំលិខិតអនុញ្ញាតឲ្យយានយន្តធ្វើអាជីវកម្មដឹកជញ្ជូនផ្លូវគោកក្នុងប្រទេសឡើយ។

**ប្រការ៩.-**

សំណុំឯកសារនៃវិញ្ញាបនបត្រចុះបញ្ជីធ្វើអាជីវកម្មដឹកជញ្ជូនផ្លូវគោក និងលិខិតអនុញ្ញាតឲ្យនីតិបុគ្គលធ្វើអាជីវកម្មដឹកជញ្ជូនផ្លូវគោកក្នុងប្រទេស ត្រូវតម្កល់ទុកនៅអគ្គនាយកដ្ឋានដឹកជញ្ជូនផ្លូវគោករយៈពេលយ៉ាងតិច៤(បួន)ឆ្នាំ។

សំណុំឯកសារនៃលិខិតអនុញ្ញាតឲ្យនីតិបុគ្គលបើកសាខាធ្វើអាជីវកម្មដឹកជញ្ជូនផ្លូវគោកក្នុងប្រទេស ត្រូវតម្កល់ទុកនៅតាមមន្ទីរសាធារណការនិងដឹកជញ្ជូនរាជធានី ខេត្ត រយៈពេលយ៉ាងតិច៤(បួន)ឆ្នាំ។

**ប្រការ១០.-**

ក្រុមហ៊ុនដែលធ្វើអាជីវកម្មដឹកជញ្ជូនផ្លូវគោក ត្រូវផ្តល់របាយការណ៍អំពីទិន្នផលដឹកជញ្ជូននៅរៀងរាល់ខែ តាមទម្រង់ដូចមានចែងនៅក្នុង**ឧបសម្ព័ន្ធទី៣**នៃប្រកាសនេះ។

**ប្រការ១១.-**

ការផ្តល់វិញ្ញាបនបត្រចុះបញ្ជីធ្វើអាជីវកម្មដឹកជញ្ជូនផ្លូវគោកក្នុងប្រទេស ការផ្តល់លិខិតអនុញ្ញាតឲ្យនីតិបុគ្គលធ្វើអាជីវកម្មដឹកជញ្ជូនផ្លូវគោកក្នុងប្រទេស និងលិខិតអនុញ្ញាតឲ្យនីតិបុគ្គលបើកសាខាធ្វើអាជីវកម្មដឹកជញ្ជូនផ្លូវគោកក្នុងប្រទេស ត្រូវបង់កម្រៃសេវាសាធារណៈ តាមការកំណត់ក្នុងប្រកាសរួមរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន។

**ប្រការ១២.-**

អគ្គនាយកដ្ឋានដឹកជញ្ជូនផ្លូវគោក ត្រូវគ្រប់គ្រង តាមដាន ត្រួតពិនិត្យ និងណែនាំអនុវត្តការផ្តល់វិញ្ញាបនបត្រចុះបញ្ជីធ្វើអាជីវកម្មដឹកជញ្ជូនផ្លូវគោកក្នុងប្រទេស និងការផ្តល់លិខិតអនុញ្ញាតឲ្យនីតិបុគ្គលធ្វើអាជីវកម្មដឹកជញ្ជូនផ្លូវគោកក្នុងប្រទេសនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ១៣.-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ១៤.-**

នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានដឹកជញ្ជូនផ្លូវគោក អគ្គនាយកនៃអគ្គនាយកដ្ឋានដឹកជញ្ជូនផ្លូវទឹក ផ្លូវសមុទ្រ និងកំពង់ផែ អគ្គនាយកនៃអគ្គនាយកដ្ឋានផែនការនិងគោលនយោបាយ អគ្គនាយកនៃអគ្គនាយកដ្ឋានសាធារណការ អគ្គនាយកនៃអគ្គនាយកដ្ឋានបច្ចេកទេស អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានភស្តុភារកម្ម អគ្គាធិការនៃអគ្គាធិការដ្ឋាន ប្រធាននាយកដ្ឋានជំនាញ ប្រធានមន្ទីរសាធារណការនិងដឹកជញ្ជូនរាជធានីខេត្ត ប្រធានអង្គភាពក្រោមឱវាទក្រសួងសាធារណការនិងដឹកជញ្ជូន និងអ្នកពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តរៀងៗខ្លួន តាមខ្លឹមសារនៃប្រកាសនេះឲ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន**

**ស៊ុន ចាន់ថុល**

**កន្លែងទទួល៖**
- -ទីស្តីការគណៈរដ្ឋមន្ត្រី
- -អគ្គលេខាធិការរាជរដ្ឋាភិបាល
- -ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី
- -ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រីប្រចាំការ
- -ក្រសួងស្ថាប័នពាក់ព័ន្ធ
- -សាលារាជធានី ខេត្ត

"ដើម្បីជូនជ្រាប"
- -ដូចប្រការ១៤

"ដើម្បីអនុវត្ត"
- -ឯកសារ កាលប្បវត្តិ

## ឧបសម្ព័ន្ធទី១

គំនូសបំព្រួញអំពីដំណើរការផ្តល់លិខិតអនុញ្ញាតឲ្យនីតិបុគ្គលធ្វើអាជីវកម្មដឹកជញ្ជូនផ្លូវគោកក្នុងប្រទេស និងការផ្តល់លិខិតអនុញ្ញាតឲ្យនីតិបុគ្គលបើកសាខាធ្វើអាជីវកម្មដឹកជញ្ជូនផ្លូវគោកក្នុងប្រទេស

ប្រកាសលេខ..................ចុះថ្ងៃទី............ខែ............ឆ្នាំ...................

ស្តីពីលក្ខខណ្ឌ និងនីតិវិធីនៃការចេញលិខិតអនុញ្ញាតឲ្យនីតិបុគ្គលធ្វើអាជីវកម្មដឹកជញ្ជូនផ្លូវគោកក្នុងប្រទេស




**សម្គាល់៖** ប្រព័ន្ធស្វ័យប្រវត្តិកម្មស្នើសុំធ្វើអាជីវកម្មដឹកជញ្ជូនផ្លូវគោក មានអាសយដ្ឋាន

transportlicense.mpwt.gov.kh

# ឧបសម្ព័ន្ធទី២

ទម្រង់ពាក្យសុំវិញ្ញាបនបត្រចុះបញ្ជីធ្វើអាជីវកម្មដឹកជញ្ជូនផ្លូវគោកក្នុងប្រទេស លិខិតអនុញ្ញាតឲ្យនីតិបុគ្គលធ្វើអាជីវកម្មដឹកជញ្ជូនផ្លូវគោកក្នុងប្រទេស ឬលិខិតអនុញ្ញាតឲ្យនីតិបុគ្គលបើកសាខាធ្វើអាជីវកម្មដឹកជញ្ជូនផ្លូវគោកក្នុងប្រទេស

និង

ទម្រង់វិញ្ញាបនបត្រចុះបញ្ជីធ្វើអាជីវកម្មដឹកជញ្ជូនផ្លូវគោកក្នុងប្រទេស លិខិតអនុញ្ញាតឲ្យនីតិបុគ្គលធ្វើអាជីវកម្មដឹកជញ្ជូនផ្លូវគោកក្នុងប្រទេស ឬលិខិតអនុញ្ញាតឲ្យនីតិបុគ្គលបើកសាខាធ្វើអាជីវកម្មដឹកជញ្ជូនផ្លូវគោកក្នុងប្រទេសដែលត្រូវបោះពុម្ពចេញពីប្រព័ន្ធស្វ័យប្រវត្តិកម្មស្នើសុំធ្វើអាជីវកម្មដឹកជញ្ជូនផ្លូវគោក ដោយមានព័ត៌មាននីតិបុគ្គលភ្ជាប់មកជាមួយស្រាប់

ប្រកាសលេខ...................... ចុះថ្ងៃទី......... ខែ.......... ឆ្នាំ..............

ស្តីពីលក្ខខណ្ឌ និងនីតិវិធីនៃការចេញលិខិតអនុញ្ញាតឲ្យនីតិបុគ្គលធ្វើអាជីវកម្មដឹកជញ្ជូនផ្លូវគោកក្នុងប្រទេស

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

## ពាក្យសុំវិញ្ញាបនបត្រចុះបញ្ជីធ្វើអាជីវកម្មដឹកជញ្ជូនផ្លូវគោកក្នុងប្រទេស

នាមនិងគោត្តនាម.......................................................................ភេទ...........សញ្ជាតិ..............

អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ សៀវភៅគ្រួសារ ឬសៀវភៅស្នាក់នៅ ឬលិខិតឆ្លងដែន...........................

ក្រុមហ៊ុននាម..............................................................................................................

អាសយដ្ឋានបច្ចុប្បន្ន -ផ្ទះលេខ...............ផ្លូវ...............ភូមិ......................សង្កាត់/ឃុំ..............

ខណ្ឌ/ក្រុង/ស្រុក.............................រាជធានី/ខេត្ត.............................លេខទូរស័ព្ទ.........................

អ៊ីម៉ែល.......................................................កម្មវត្ថុអាជីវកម្ម................................................។

ធ្វើនៅ....................ថ្ងៃទី.......ខែ...........ឆ្នាំ...............

ហត្ថលេខា និងត្រាក្រុមហ៊ុន

**ឯកសារភ្ជាប់៖**

- អត្តសញ្ញាណរបស់ប្រធានក្រុមហ៊ុន៖
  - អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ សៀវភៅគ្រួសារ ឬសៀវភៅស្នាក់នៅ(ករណីក្រុមហ៊ុនសញ្ជាតិខ្មែរ)
  - លិខិតឆ្លងដែន(ករណីក្រុមហ៊ុនសញ្ជាតិបរទេស)
- វិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម
- លក្ខន្តិកៈក្រុមហ៊ុន
- បណ្ណប៉ាតង់

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

## ពាក្យសុំលិខិតអនុញ្ញាតឲ្យនីតិបុគ្គលបើកសាខាធ្វើអាជីវកម្មដឹកជញ្ជូនផ្លូវគោកក្នុងប្រទេស

នាមនិងគោត្តនាម..........................................................ភេទ............សញ្ជាតិ................

អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ សៀវភៅគ្រួសារ ឬសៀវភៅស្នាក់នៅ ឬលិខិតឆ្លងដែន............................

មានក្រុមហ៊ុននាម.......................................................................................................................

អាសយដ្ឋានបច្ចុប្បន្ន -ផ្ទះលេខ..............ផ្លូវ...................ភូមិ....................សង្កាត់/ឃុំ.................

ខណ្ឌ/ក្រុង/ស្រុក...........................រាជធានី/ខេត្ត................................លេខទូរស័ព្ទ.................

អ៊ីម៉ែល....................................... កម្មវត្ថុអាជីវកម្ម.....................................................................

អាសយដ្ឋានសាខាផ្ទះលេខ..............ផ្លូវ...................ភូមិ...................សង្កាត់/ឃុំ.........................

ខណ្ឌ/ក្រុង/ស្រុក...........................រាជធានី/ខេត្ត...........................................................................។

ធ្វើនៅ.....................ថ្ងៃទី.......ខែ............ឆ្នាំ..............

ហត្ថលេខា និងត្រាក្រុមហ៊ុន

**ឯកសារភ្ជាប់៖**

- វិញ្ញាបនបត្រចុះបញ្ជីធ្វើអាជីវកម្មដឹកជញ្ជូនផ្លូវគោកក្នុងប្រទេស
- លិខិតអនុញ្ញាតឲ្យនីតិបុគ្គលធ្វើអាជីវកម្មដឹកជញ្ជូនផ្លូវគោកក្នុងប្រទេស
- លិខិតបញ្ជាក់អំពីទីស្នាក់ការសាខាក្រុមហ៊ុន
- បណ្ណប៉ាតង់

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
NATION RELIGION KING

ក្រសួងសាធារណការ និងដឹកជញ្ជូន
MINISTRY OF PUBLIC WORKS AND TRANSPORT
លេខ(No)៖..........................................

# វិញ្ញាបនបត្រចុះបញ្ជីធ្វើអាជីវកម្មដឹកជញ្ជូនផ្លូវគោកក្នុងប្រទេស
## TRANSPORT OPERATION LICENSE

នាមករណ៍ក្រុមហ៊ុន..........................................................................................

ចុះបញ្ជីលេខ..............................................................ចុះថ្ងៃទី...........ខែ..................ឆ្នាំ.........................

អាសយដ្ឋាន ..............................................................................................

Company name..........................................................................................

Registration Number..........................................................Date.........................................................

Address..........................................................................................

លិខិតអនុញ្ញាតនេះ មិនចាំបាច់មានហត្ថលេខា
The Signature is not required inLicense

សម្គាល់៖លិខិតអនុញ្ញាតឲ្យនីតិបុគ្គលធ្វើអាជីវកម្មដឹកជញ្ជូនផ្លូវគោកក្នុងប្រទេសមានទំហំ A4

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
NATION RELIGION KING

ក្រសួងសាធារណការ និងដឹកជញ្ជូន
MINISTRY OF PUBLIC WORKS AND TRANSPORT
អគ្គនាយកដ្ឋានដឹកជញ្ជូនផ្លូវគោក
GENERAL DEPARTMENT OF LAND TRANSPORT
លេខ(No)៖..............................................

# លិខិតអនុញ្ញាតឲ្យនីតិបុគ្គលធ្វើអាជីវកម្មដឹកជញ្ជូនផ្លូវគោកក្នុងប្រទេស
## CERTIFICATE OF DOMESTIC TRANSPORT OPERATION

នាមករណ៍ក្រុមហ៊ុន..............................................................................................

វិញ្ញាបនបត្រចុះធ្វើអាជីវកម្មដឹកជញ្ជូនលេខ..............................ចុះថ្ងៃទី..........ខែ..............ឆ្នាំ..............

កម្មវត្ថុអាជីវកម្ម..............................................................................................

អាសយដ្ឋាន ..............................................................................................

កាលបរិច្ឆេទចេញ..............................កាលបរិច្ឆេទផុតសុពលភាព..............................។

Company name..............................................................................................

Registration Number..............................Date..............................

Business Objective..............................................................................................

Address..............................................................................................

Date of Issue..............................Date of Expiry..............................

លិខិតអនុញ្ញាតនេះ មិនចាំបាច់មានហត្ថលេខា
The Signature is not required in this License

សម្គាល់៖លិខិតអនុញ្ញាតឲ្យនីតិបុគ្គលធ្វើអាជីវកម្មដឹកជញ្ជូនផ្លូវគោកក្នុងប្រទេសមានទំហំ A4

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
KINGDOM OF CAMBODIA
NATION RELIGION KING

**ក្រសួងសាធារណការ និងដឹកជញ្ជូន**
MINISTRY OF PUBLIC WORKS AND TRANSPORT
**មន្ទីរសាធារណការ និងដឹកជញ្ជូន រាជធានី ខេត្ត...............**
PROVINCIAL DEPARTMENT OF PUBLIC WORKS AND TRANSPORT...............
លេខ(No)៖..........................................

## លិខិតអនុញ្ញាតឲ្យនីតិបុគ្គលបើកសាខាធ្វើអាជីវកម្មដឹកជញ្ជូនផ្លូវគោកក្នុងប្រទេស
## BRANCH OF DOMESTIC TRANSPORT OPERATION LICENSE

នាមករណ៍ក្រុមហ៊ុន..........................................................................................................

លិខិតវិញ្ញាបនបត្រចុះធ្វើអាជីវកម្មដឹកជញ្ជូនផ្លូវគោកក្នុងប្រទេសលេខ..........................ចុះថ្ងៃទី............ខែ............ឆ្នាំ..............

កម្មវត្ថុអាជីវកម្ម..........................................................................................................

ទីស្នាក់ការសាខា..........................................................................................................

កាលបរិច្ឆេទចេញ..................................................កាលបរិច្ឆេទផុតសុពលភាព..................................................។

Company name..........................................................................................................

Registration Number..................................................Date..................................................

Business Objective..........................................................................................................

Address..........................................................................................................

Date of Issue..................................................Date of Expiry..................................................

| |
|---|
| លិខិតអនុញ្ញាតនេះ មិនចាំបាច់មានហត្ថលេខា<br>The Signature is not required in this License |

សម្គាល់៖លិខិតអនុញ្ញាតឲ្យនីតិបុគ្គលធ្វើអាជីវកម្មដឹកជញ្ជូនផ្លូវគោកក្នុងប្រទេសមានទំហំ A4

## ឧបសម្ព័ន្ធទី៣

ទម្រង់របាយការណ៍អំពីទិន្នផលដឹកជញ្ជូន

ប្រកាសលេខ...................... ចុះថ្ងៃទី.........ខែ..............ឆ្នាំ.........

ស្តីពីលក្ខខណ្ឌនិងនីតិវិធីនៃការចេញលិខិតអនុញ្ញាតឲ្យនីតិបុគ្គលធ្វើអាជីវកម្មដឹកជញ្ជូនផ្លូវគោក ក្នុងប្រទេស

ដែលត្រូវបោះពុម្ពចេញពីប្រព័ន្ធស្វ័យប្រវត្តិកម្មស្នើសុំធ្វើអាជីវកម្មដឹកជញ្ជូនតាមផ្លូវគោក ដោយមានទិន្នន័យភ្ជាប់មកជាមួយស្រាប់

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមហ៊ុន៖**..................................................................................................

លេខលិខិតអនុញ្ញាតឲ្យនីតិបុគ្គធ្វើអាជីវកម្មដឹកជញ្ជូនផ្លូវគោកក្នុងប្រទេស៖..........................................

### របាយការណ៍អំពីទិន្នផលដឹកជញ្ជូនទំនិញ

**ពីថ្ងៃទី............ខែ................ឆ្នាំ.............ដល់ថ្ងៃទី............ខែ..................ឆ្នាំ..........**

| លរ. | ចំនួនយានយន្ត (A) | ទម្ងន់ផ្ទុក (តោន) (B) | ប្រភេទទំនិញ | សរុបទម្ងន់ផ្ទុក(តោន) (C)=(A)x(B) | ទិសដៅ | សេចក្តីបញ្ជាក់ផ្សេងៗ |
|---|---|---|---|---|---|---|
| ១<br>២<br>៣<br>. | | | | | | |

### របាយការណ៍អំពីទិន្នផលដឹកជញ្ជូនអ្នកដំណើរ

**ពីថ្ងៃទី............ខែ................ឆ្នាំ.............ដល់ថ្ងៃទី............ខែ..................ឆ្នាំ..........**

| លរ. | ចំនួនយានយន្ត (A) | ចំនួនកៅអី (នាក់) (B) | សរុបចំនួនអ្នកដំណើរ(នាក់) (ជាក់ស្តែង) (C)=(A)x(B) | ទិសដៅ | សេចក្តីបញ្ជាក់ផ្សេងៗ |
|---|---|---|---|---|---|
| ១<br>២<br>៣<br>. | | | | | |